ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ចាម

លេខ ២៥ (ឆ)/២៣
ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣

# សាលក្រម

ក្នុងនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងខេត្តកំពង់ចាម

**បានចេញសាលក្រមដែលមានខ្លឹមសារដូចតទៅ:**

សញ្ញាណរឿងក្តី ៖ សំណុំរឿងរដ្ឋប្បវេណីលេខ ៦២ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១
ប្រភេទរឿងក្តី ៖ បណ្តឹងទាមទារលែងលះ
ថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ៖ ថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣
ចៅក្រមជំនុំជម្រះ ៖ លោក [redacted]
ក្រឡាបញ្ជីសវនាការ ៖ លោក [redacted]

## គូភាគីនៃរឿងក្តី

### ដើមចោទ

ឈ្មោះ [redacted] ស្រីមុំ ភេទស្រី កើតថ្ងៃទី២ ខែសីហា ឆ្នាំ១៩៨៦ ជនជាតិខ្មែរ មុខរបរ កសិករ អាសយដ្ឋាន [redacted] ។

**អ្នកតំណាងដោយអាណត្តិ:** លោក [redacted] អត្តលេខ ២៥៤១T ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា [redacted] (លិខិតតំណាងដោយអាណត្តិលេខ ៤៦ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២២) ។

### ចុងចម្លើយ

ឈ្មោះ [redacted] សុខុន ភេទប្រុស កើតថ្ងៃទី៥ ខែកក្កដា ឆ្នាំ១៩៨៤ ជនជាតិខ្មែរ មុខរបរ កម្មករ អាសយដ្ឋានរស់ [redacted] ។

## អង្គហេតុ និងចំណុចវិវាទ

### ១-ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ

ក-ប្តឹងសុំលែងលះពីចុងចម្លើយឈ្មោះ [redacted] សុខុន ។
ខ-សុំសិទ្ធិគ្រប់គ្រងកូនឈ្មោះ [redacted] លីងហ័ង ភេទស្រី កើតថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៧ ។
គ-ទាមទារប្រាក់អាហារកិច្ចចិញ្ចឹមកូនផ្តាច់ចំនួន ២០.០០០ (ម្ភៃពាន់) ដុល្លារអាមេរិក ។
ឃ-ប្រាក់ប្រដាប់ក្តីគឺជាបន្ទុករបស់ចុងចម្លើយ ។

### ២-ដំណើររឿងក្តី និងចំណុចវិវាទ

#### ក-ការសង្ខេបអំពីរឿងក្តី

ដើមចោទ និងចុងចម្លើយ គឺជាប្តីប្រពន្ធដែលបានរៀបការតាមប្រពៃណីកាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានឃុំក្រឡា (ស្រុកកំពង់សៀម) កាលពីថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៩ ដូចមានបញ្ជាក់ដោយសំបុត្រអាពាហ៍ពិពាហ៍លេខ ១២ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៩ ។ នៅក្នុងការរួមរស់ជាមួយគ្នាជាប្តីប្រពន្ធ ភាគីទាំងពីរបង្កើតបានកូនម្នាក់ឈ្មោះ [redacted] លីងហ័ង ភេទស្រី កើតថ្ងៃទី១៥



Scanned with CamScanner

ខែកញ្ញា ឆ្នាំ២០១៧ ដូចមានបញ្ជាក់ដោយសំបុត្រកំណើតលេខ ៧៣ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៩ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំក្រឡា ។ នៅក្នុងឆ្នាំ២០១៩ ចុងចម្លើយបានចេញទៅធ្វើការជាពលករនៅប្រទេសកូរ៉េ ពីដំបូងឡើយបានផ្ញើប្រាក់មកផ្គត់ផ្គង់គ្រួសារជួនកាលមួយខែម្តង ជួនកាលពីរទៅបីខែទើបផ្ញើប្រាក់ម្តង ម្តងៗមានចំនួន ១០០ ដុល្លារអាមេរិក ទៅ ២០០ ដុល្លារអាមេរិក ហើយផ្ញើបានតែបីដងប៉ុណ្ណោះតាមតែចិត្តរបស់ចុងចម្លើយ ពេលណាចង់ផ្ញើក៏ផ្ញើមក ពេលណាមិនចង់ផ្ញើក៏ប្តូរលេខ និងហ្វេសប៊ុករបស់ដើមចោទធ្វើឲ្យដើមចោទមិនអាចទាក់ទងជាមួយចុងចម្លើយបាននោះទេ ។ ដោយសារមូលហេតុនេះហើយ ធ្វើឲ្យដើមចោទអស់មនោសញ្ចេតនាជាមួយនឹងចុងចម្លើយ ហើយបានប្តឹងទាមទារសុំឲ្យតុលាការចេញសាលក្រមដូចមានក្នុងកម្មវត្ថុទាមទារ (**ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ**) ខាងលើ ដោយផ្អែកលើមូលហេតុនៃការលែងលះ ។

## ខ-លទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការបានកោះហៅចុងចម្លើយដើម្បីចូលរួមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយបានបញ្ជូនដីកាកោះដល់ចុងចម្លើយរួចហើយ ដោយមានស្នាមមេដៃផ្តិតនៅលើដីកាកោះ និងមានអក្សរសរសេរដោយផ្ទាល់ដៃរបស់ចុងចម្លើយដែលមានខ្លឹមសារ៖ "ខ្ញុំបាទឈ្មោះ [redacted] សុខុន បានទទួលដីកាកោះនេះនៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ ម៉ោង ២ រសៀល ដោយខ្ញុំបានទទួលដីកានកោះនេះ ខ្ញុំបានេកភាពទៅតាមបណ្តឹងសុំរបស់ដើមចោទដោយសុខចិត្តប្រគល់ប្រាក់ចំនួន ៤០០០$ ជួយចិញ្ចឹមកូនផ្ទាច់ដោយអោយតាមរយៈឪពុកម្តាយខ្ញុំ ហើយនៅកាលបរិច្ឆេទដែលបានកំណត់ចុងចម្លើយអវត្តមានដោយមានលិខិតឆ្លើយតបរបស់ចុងចម្លើយ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣ ។

ក្រោយបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលរួចមក តុលាការបានកំណត់ចំណុចវិវាទ និងភស្តុតាងដូចខាងក្រោម៖

**ក-ចំណុចវិវាទនៃរឿងក្តី:** *តើមូលហេតុដែលដើមចោទប្តឹងសុំលែងលះពីចុងចម្លើយ អាចទទួលស្គាល់ថាជាមូលហេតុនៃការលែងលះដែរ ឬទេ ?*

**ខ-ភស្តុតាងដែលមាននៅក្នុងសំណុំរឿង**

*ភស្តុតាងដែលទទួលបានពីដើមចោទ (X)*

ភស្តុតាងជាឯកសារ

X ១ : សំបុត្រអាពាហ៍ពិពាហ៍លេខ ១២ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៩ ។

X ២ : សំបុត្រកំណើត (ឈ្មោះ [redacted]លីងហ៊ាង) លេខ ៧៣ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៩ ។

X ៣ : លិខិតឆ្លើយតបរបស់ចុងចម្លើយ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣ ។

X ៤ : ចំណាររលើខ្នងដីកាកោះដែលសរសេរដោយផ្ទាល់ដៃរបស់ចុងចម្លើយឈ្មោះ ថន សុខុន ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២៣ ។

X ៥ : លិខិតប្រគល់-ទទួលប្រាក់ថ្លៃអាហារកិច្ចចិញ្ចឹមកូន ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ រវាងឈ្មោះ [redacted] ឈឿន ឈ្មោះ[redacted]ផៃ និងឈ្មោះ[redacted]ស្រីមុំ ។

ការសាកសួរសាក្សី

X ៦ : សាក្សីឈ្មោះ [redacted] ឈឿន ភេទប្រុស កើតថ្ងៃទី១៣ ខែមិថុនា ឆ្នាំ១៩៥៦ (ត្រូវជាឪពុកបង្កើតចុងចម្លើយ) និងឈ្មោះ[redacted]ផៃ ភេទស្រី កើតថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៥៩ (ជាម្តាយបង្កើតចុងចម្លើយ) អាសយដ្ឋានរស់នៅភូមិត្រពាំងបឹង ឃុំថ្មពូន ស្រុកព្រៃឈរ ខេត្តកំពង់ចាម (ត្រូវជាឪពុកបង្កើតរបស់ចុងចម្លើយ) ។

## ៣-ការអះអាងរបស់គាគីស្តីពីចំណុចវិវាទ

ដើមចោទឈ្មោះ[redacted] ស្រីមុំ ថ្លែងការណ៍ថា ខ្លួន និងចុងចម្លើយបានរៀបការតាមប្រពៃណីកាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៩ នៅសាលាឃុំក្រឡា ដូចមាន



Scanned with CamScanner

បញ្ជាក់ដោយសំបុត្រអាពាហ៍ពិពាហ៍លេខ ១២ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៩ ។ ក្នុងការរួមរស់ជាមួយគ្នាជាប្តីប្រពន្ធ ខ្លួនទាំងពីរបង្កើតបានកូនម្នាក់ឈ្មោះ [redacted] លីងហ៊ាង ភេទស្រី កើតថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៧ ដូចមានបញ្ជាក់ដោយសំបុត្រកំណើតលេខ ៧៣ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៩ ចំណែកទ្រព្យសម្បត្តិរួម និងបំណុលពុំមាននោះទេ។ ដោយសារបញ្ហាជីវភាព នៅក្នុងឆ្នាំ២០១៩ ប្តីរបស់ខ្លួនបានចេញទៅធ្វើការជាពលករនៅប្រទេសកូរ៉េខាងត្បូង ។ ដំបូងឡើយគាត់បានផ្ញើប្រាក់ឲ្យមកខ្លួន ប៉ុន្តែពុំច្រើននោះទេ សរុបទៅបានប្រហែល ៧០០$ តែប៉ុណ្ណោះ ហើយចាប់តាំងពីពេលនោះមក ចុងចម្លើយឈប់ផ្ញើប្រាក់មកឲ្យខ្លួន និងកូន ហើយក៏មិនដែលទំនាក់ទំនងមកខ្លួនដែរ ខ្លួនក៏មិនអាចទាក់ទងបានដោយសារតែគាត់បានប្តូកលេខ និងហ្វេសប៊ុករបស់ខ្លួន ។ សព្វថ្ងៃនេះ ខ្លួន និងចុងចម្លើយបានរស់នៅបែកគ្នា និងពុំមានទំនាក់ទំនងគ្នានោះទេ ។ នៅក្នុងពាក្យបណ្តឹងខ្លួនបានប្តឹងទាមទារចំនួន ៣ ចំណុច គឺ៖

ក-ប្តឹងសុំលែងលះពីចុងចម្លើយឈ្មោះ [redacted] សុខុន ។

ខ-សុំសិទ្ធិគ្រប់គ្រងកូនឈ្មោះ [redacted] លីងហ៊ាង ភេទស្រី កើតថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៧ ។

គ-ទាមទារប្រាក់អាហារកិច្ចចិញ្ចឹមកូនផ្តាច់ចំនួន ២០.០០០ (ម្ភៃពាន់) ដុល្លារអាមេរិក ។

**ក-អំពីការលែងលះ**

មូលហេតុដែលខ្លួនសុំលែងលះពីចុងចម្លើយ ដោយសារតែចុងចម្លើយធ្វើការបានប្រាក់ខែប៉ុន្តែពុំបានផ្ញើប្រាក់ផ្គត់ផ្គង់គ្រួសារនោះទេ ខ្លួនត្រូវចិញ្ចឹមកូនតែម្នាក់ឯង គ្មានទំនួលខុសត្រូវក្នុងនាមជាមេគ្រួសារនោះទេ ហើយម្យ៉ាងទៀតរវាងខ្លួន និងចុងចម្លើយ ថ្វីត្បិតតែជាប្តីប្រពន្ធមែន ប៉ុន្តែជាក់ស្តែងពុំដែលទំនាក់ទំនងគ្នានោះទេ រស់នៅផ្សេងគ្នាហាក់បីដូចជាអ្នកដទៃ ផ្តាច់ទំនាក់ទំនងគ្នាប្រហែលជាងបីឆ្នាំមកងហើយ ។

**ខ-អំពីការសុំសិទ្ធិគ្រប់គ្រងកូន**

មូលហេតុដែលខ្លួនប្តឹងសុំសិទ្ធិជាអ្នកមានអំណាចមេបាលើឈ្មោះ [redacted] លីងហ៊ាង ភេទស្រី កើតថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៧ ដោយសារតែពេលចុងចម្លើយចេញទៅធ្វើការនៅកូរ៉េ កូនទើបតែបានអាយុប្រហែលមួយខួប គឺកូននៅខ្លួនមើលថែរក្សារហូតមក ហើយគាត់ពុំបានជួយចិញ្ចឹមបីបាច់ថែរក្សាកូននោះទេ លុយក៏មិនបានផ្ញើចិញ្ចឹមកូន មានតែខ្លួនជាម្តាយបានមើលថែរក្សារហូតមក ហើយម្យ៉ាងទៀតកូននៅតូចត្រូវការខ្លួនជាម្តាយមើលថែរក្សា ។

**គ-អំពីការទាមទារប្រាក់អាហារកិច្ចចិញ្ចឹមកូន**

ពីដំបូងឡើយ នៅពេលដាក់ពាក្យបណ្តឹង ខ្លួនប្តឹងទាមទារប្រាក់អាហារកិច្ចចិញ្ចឹមកូនផ្តាច់ពីចុងចម្លើយចំនួន ២០.០០០ (ម្ភៃពាន់) ដុល្លារអាមេរិក ប៉ុន្តែក្រោយមកដោយមានការចរចារសម្របសម្រួលគ្នា ចុងចម្លើយបានសូមបង់ផ្តាច់ចំនួន ៤.០០០ (បួនពាន់) ដុល្លារអាមេរិក ខ្លួនក៏បានយល់ព្រមទទួលយកប្រាក់ចំនួន ៤.០០០ (បួនពាន់) ដុល្លារអាមេរិកដើម្បីបញ្ចប់រឿងកុំអោយមានបញ្ហាវែងឆ្ងាយទៅថ្ងៃក្រោយ ដូចមានបញ្ជាក់នៅក្នុងលិខិតប្រគល់-ទទួលប្រាក់ថ្លៃអាហារកិច្ចចិញ្ចឹមកូន ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ ។ ដូច្នេះនៅពេលនេះ ខ្លួនពុំប្តឹងទាមទារប្រាក់អាហារកិច្ចចិញ្ចឹមកូនពីចុងចម្លើយនោះទេ ។

សាក្សីឈ្មោះ [redacted] ឈឿន និងឈ្មោះ [redacted] ផៃ ឆ្លើយថា ខ្លួនទាំងពីរនាក់ត្រូវជាឪពុកម្តាយបង្កើតរបស់ឈ្មោះ [redacted] សុខុន ។ សាក្សីទាំងពីរនាក់បានឆ្លើយប្រហាក់ប្រហែលគ្នាថា តាមការបញ្ជាក់ គឺកូនរបស់ខ្លួនឈ្មោះ [redacted] សុខុន បានយល់ព្រមលែងលះពីដើមចោទឈ្មោះ [redacted] ស្រីមុំ ដោយបានប្រាប់ខ្លួនថា បើប្រពន្ធចង់លែងលះស្រេចតាមតែគេទៅ ព្រោះខ្លួនសព្វថ្ងៃមានជម្ងឺ ហើយគ្មានលទ្ធភាពចិញ្ចឹមកូន និងប្រពន្ធដែរ ហើយណាមួយខ្លួនឈឺ សុខភាពមិនសូវល្អ រកប្រាក់ចំណូលមិនសូវបាននោះទេ ។ កូនរបស់ខ្លួនក៏មានបំណងចង់លែងលះជាមួយដើមចោទផងដែរ ហើយពាក់ព័ន្ធនឹងការទាមទារប្រាក់អាហារកិច្ចចិញ្ចឹមកូន កូនប្រុសបានប្រគល់ប្រាក់អាហារកិច្ចចិញ្ចឹមកូនចំនួន ៤.០០០ (បួនពាន់) ដុល្លារអាមេរិក ឲ្យទៅដើមចោទឈ្មោះ [redacted] ស្រីមុំ រួចហើយកាលពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ ។ ចំពោះទំនាក់ទំនងរវាងកូនខ្លួនឈ្មោះ [redacted] សុខុន និងកូនប្រសារឈ្មោះ [redacted] ស្រីមុំ គឺពេលទៅកូរ៉េដំបូង ប្រហែលប្រាំមួយទៅប្រាំពីរខែដំបូង គឺនៅមានទំនាក់ទំនងគ្នាធម្មតា ប៉ុន្តែក្រោយៗមកទៀតលែងមានទំនាក់ទំនងនឹងគ្នាមិនដឹងមូលហេតុអ្វីនោះទេ ហើយសម្រាប់ខ្លួនទាំងពីរនាក់ជាឪពុកម្តាយ ក៏កូនពុំសូវបានទំនាក់ទំនងមកដែរ ។



Scanned with CamScanner

## ការទាញហេតុផលចុងក្រោយ

លោក [redacted] ប៉ុម ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ ធ្វើការទាញហេតុផលចុងក្រោយដូចតទៅៈ ដោយសារនៅក្នុងរឿងនេះ ភាគីទាំងសងខាងបានព្រមព្រៀងគ្នារួចអស់ហើយ និងបានប្រគល់ប្រាក់អាហារកិច្ចចិញ្ចឹមបីបាច់ថែរក្សាកូនរួចហើយ ហេតុដូច្នេះស្នើសុំតុលាការចេញសាលក្រមសម្រេចតាមការទាមទាររបស់ដើមចោទ ដោយសម្រេចលែងលះដើមចោទ និងចុងចម្លើយលែងលះ និងសម្រេចឲ្យដើមចោទ គឺជាអ្នកមានអំណាចមេបាលើកូនឈ្មោះ [redacted] លីងហ៊ាង ភេទស្រី កើតថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៧ ។ ដោយឡែកចំពោះប្រាក់អាហារកិច្ចចិញ្ចឹមបីបាច់ថែរក្សាកូន ដើមចោទបានទទួលរួចហើយ ហេតុដូច្នេះពុំចាំបាច់សម្រេចនៅក្នុងសាលក្រមនោះទេ ។

ដើមចោទឈ្មោះ [redacted] ស្រីមុំ ធ្វើការទាញហេតុផលចុងក្រោយដូចតទៅៈ នៅក្នុងរឿងនេះ ខ្លួននៅតែរក្សាការទាមទារលែងលះ និងសុំសិទ្ធិគ្រប់គ្រងអំណាចមេបាលើកូន ហេតុដូច្នេះស្នើសុំតុលាការចេញសាលក្រមសម្រេចតាមការទាមទារ ។

## សំអាងហេតុ

**ស្តីអំពីចំណុចវិវាទនៃរឿងក្តី:** *តើមូលហេតុដែលដើមចោទប្តឹងសុំលែងលះពីចុងចម្លើយ អាចទទួលស្គាល់ថាជាមូលហេតុនៃការលែងលះដែរ ឬទេ ?*

ផ្អែកតាមលទ្ធផលនៃការពិនិត្យភស្តុតាងនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់
តុលាការយល់ឃើញថា

**១-ការវិនិច្ឆ័យអំពីការទាមទារ**

**ការទាមទារចំណុចទី១ ៖** ការទាមទារលែងលះ

*មាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី៖ មូលហេតុនៃការលែងលះ*

*ប្តី ឬប្រពន្ធ អាចដាក់ពាក្យបណ្តឹងលែងលះគ្នាបានតែក្នុងករណីដែលកំណត់ខាងក្រោម៖*

*ក-បើបានប្រព្រឹត្តអំពើផិតទៅលើសហព័ទ្ធ ។*

*ខ-បើបានបោះបង់សហព័ទ្ធចោលដោយគ្មានមូលហេតុត្រឹមត្រូវ ។*

*គ-បើមិនដឹងច្បាស់ថាសហព័ទ្ធស្លាប់ ឬ រស់ អស់រយៈពេលជាង ១ (មួយ) ឆ្នាំ ។*

*ឃ-បើសហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់អស់រយៈពេលជាង ១ (មួយ) ឆ្នាំ ផ្ទុយទៅនឹងគោលបំណងអាពាហ៍ពិពាហ៍ ។*

*ង-ករណីផ្សេងទៀតដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន ។*

ក-ផ្អែកតាមមាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី ដើមចោទអាចប្តឹងសុំទាមទារលែងលះពីចុងចម្លើយ លុះត្រាតែមានមូលហេតុណាមួយដូចមានរៀបរាប់ក្នុងមាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី ចាប់ពី **ចំណុច ក ដល់ ង** ។

ខ-នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ តុលាការបានកោះហៅចុងចម្លើយ ដោយចុងចម្លើយបានទទួលដីកាកោះរួចហើយ ប៉ុន្តែអវត្តមាននៅកាលបរិច្ឆេទដែលតុលាការបានកំណត់ ។ ទោះបីចុងចម្លើយអវត្តមានពុំបានបង្ហាញខ្លួនតាមកាលបរិច្ឆេទ ប៉ុន្តែផ្អែកតាមលទ្ធផលនៃការសាកសួរដើមចោទឈ្មោះ [redacted] ស្រីមុំ សាក្សីឈ្មោះ [redacted] ឈឿន ឈ្មោះ [redacted] ផៃ និងតាមការពិនិត្យភស្តុតាង (X3) និង (X4) តុលាការទទួលស្គាល់ថា រវាងដើមចោទ និងចុងចម្លើយពិតជាបានរស់នៅបែកគ្នាដោយគ្មានដំណឹងអស់រយៈពេលច្រើនឆ្នាំមកហើយ គឺតាំងពីឆ្នាំ២០១៩ រហូតមកដល់បច្ចុប្បន្ននេះ ហើយការរស់នៅបែកគ្នានេះ គឺដើមចោទ និងចុងចម្លើយពុំបានទំនាក់ទំនងគ្នាជាលក្ខណៈប្តីប្រពន្ធទាល់តែសោះ ផ្ទុយនឹងគោលបំណងនៃអាពាហ៍ពិពាហ៍ដែលស្តែងឲ្យឃើញថា



Scanned with CamScanner

ចុងចម្លើយបានបោះបង់ដើមចោទដោយគ្មានមូលហេតុត្រឹមត្រូវ ដែលច្បាប់បញ្ញត្តិថាជាមូលហេតុនៃការលែងលះតាមមាត្រា ៩៧៨ ចំណុច ខ និង ឃ នៃក្រមរដ្ឋប្បវេណី ។

គ-ក្រៅពីមូលហេតុដូចបានលើកឡើងក្នុងចំណុច (ខ) ខាងលើ ផ្អែកតាមសេចក្តីថ្លែងការណ៍របស់ដើមចោទ និងតាមការពិនិត្យភស្តុតាង (X3) និង (X4) តុលាការទទួលស្គាល់ថា ទំនាក់ទំនងអាពាហ៍ពិពាហ៍រវាងដើមចោទ និងចុងចម្លើយត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាននោះទេ ដែលនេះគឺជាមូលហេតុនៃការលែងលះស្របតាមមាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី ចំណុច ង ។

ឃ-ដោយសារការប្តឹងទាមទាររបស់ដើមចោទ មានមូលហេតុនលែងលះដូចមានកំណត់នៅក្នុងមាត្រា ៩៧៨ ចំណុច ខ ឃ និង ង នៃក្រមរដ្ឋប្បវេណី គប្បីទទួលស្គាល់ការទាមទារ ។

**ការទាមទារចំណុចទី២ ៖ ការកំណត់អ្នកមានអំណាចមេបា**

ក-ផ្អែកតាមភស្តុតាង (X ២) អាចបញ្ជាក់បានថាឈ្មោះ [redacted] លីងហ៉ង ភេទស្រី កើតថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៧ គឺជាកូនរបស់ដើមចោទ និងចុងចម្លើយ ហើយស្ថិតក្នុងវ័យជាអនីតិជននៅឡើយ ។ ហេតុដូច្នេះនៅពេលសម្រេចអំពីការលែងលះឪពុកម្តាយ តុលាការត្រូវសម្រេចអំពីអ្នកមានអំណាចមេបាលើកូនដោយកំណត់យក ឪពុក ឬម្តាយ ជាអ្នកមានអំណាចមេបា ផ្អែកតាមការពិភាក្សារបស់ឪពុកម្តាយ ។

ខ-ផ្អែកតាមភស្តុតាង (X ៣) (X ៤) និង (X ៥) បញ្ជាក់ឲ្យឃើញថាទោះបីចុងចម្លើយអវត្តមាននាពេលទាញហេតុផលក៏ដោយ ប៉ុន្តែចុងចម្លើយបានបង្ហាញឆន្ទៈយល់ព្រមប្រគល់អំណាចមេបាលើកូនឈ្មោះ [redacted] លីងហ៉ង ភេទស្រី កើតថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៧ ឲ្យទៅដើមចោទ ។

គ-ចំពោះការបង្ហាញឆន្ទៈរបស់ចុងចម្លើយ ផ្អែកតាមសេចក្តីថ្លែងការណ៍របស់ដើមចោទក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឃើញថាឈ្មោះ [redacted] លីងហ៉ង ភេទស្រី កើតថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៧ បានរស់នៅជាមួយនឹងដើមចោទតាំងពីតូចរហូតដល់បច្ចុប្បន្ន គប្បីតុលាការកំណត់យកដើមចោទជាអ្នកមានអំណាចមេបាលើកូនស្រីម្នាក់នេះក្រោយពេលលែងលះតាមការព្រមព្រៀងរបស់ភាគី ។ មូលហេតុដែលតុលាការសម្រេចបែបនេះព្រោះជឿជាក់ថាដើមចោទពិតជាអាចចិញ្ចឹមបីបាច់ថែរក្សានិងអប់រំកូនបានល្អជាងចុងចម្លើយ ព្រោះតាំងពីកើតមកកូនស្រីម្នាក់នេះបានរស់នៅជាមួយម្តាយរហូតមក ហើយម្យ៉ាងទៀតឈ្មោះ [redacted] លីងហ៉ង ទើបតែមានអាយុ ៦ឆ្នាំ តែប៉ុណ្ណោះ ដែលត្រូវការការថែទាំ និងការមើលថែរក្សាពីម្តាយ ។

ឃ-ថ្វីត្បិតចុងចម្លើយ ពុំមានអំណាចមេបាលើកូនក្រោយលែងលះក៏ដោយ យោងតាមបញ្ញត្តិមាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី ចុងចម្លើយអាចចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនបាន ហេតុដូច្នេះភាគីទាំងពីរអាចពិភាក្សាគ្នាអំពីរបៀបចូលជួបប្រាស្រ័យទាក់ទងនេះ ដោយយកផលប្រយោជន៍របស់កូនជាអាទិភាព ។

**២-អំពីបន្ទុកនៃប្រាក់ប្រដាប់ក្តី**

ដោយសារតុលាការសម្រេចទទួលស្គាល់ការទាមទារចម្បងរបស់ដើមចោទ ដូច្នេះផ្អែកតាមបញ្ញត្តិមាត្រា ៦៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រាក់ប្រដាប់ក្តី គឺជាបន្ទុករបស់ចុងចម្លើយ ។

**យោងតាមការបង្ហាញភស្តុតាង អង្គហេតុ និងអង្គច្បាប់ ដូចបានបញ្ជាក់ខាងលើ**
**សាលាដំបូងខេត្តកំពង់ចាម សម្រេចសេចក្តីដូចខាងក្រោមៈ**

## សេចក្តីសម្រេចបញ្ចប់

១-លែងលះដើមចោទឈ្មោះ [redacted] ស្រីមុំ និងចុងចម្លើយឈ្មោះ [redacted] សុខុន ។

២-កំណត់យកដើមចោទឈ្មោះ [redacted] ស្រីមុំ ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ [redacted] លីងហ៉ង ភេទស្រី កើតថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៧ ។

ចុងចម្លើយមានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន ដូច្នេះហើយដើមចោទត្រូវផ្តល់លក្ខណៈងាយដល់ចុងចម្លើយក្នុងការចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន ។



Scanned with CamScanner

៣-ប្រាក់ប្រដាប់ក្ដី គឺជាបន្ទុករបស់ចុងចម្លើយ ។

*សាលក្រមនេះ ទាញហេតុផលដោយផ្ទាល់មាត់ជាអសាធារណៈ និងប្រកាសសាលក្រមថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣ ។ ករណីមិនសុខចិត្តនឹងការសម្រេចនេះភាគីអាចប្ដឹងឧទ្ធរណ៍នឹងសាលក្រមក្នុងអំឡុងពេល ១ (មួយ) ខែ គិតចាប់ពីថ្ងៃបានទទួលការបញ្ជូនលិខិតសាលក្រម ។*

**ចៅក្រមជំនុំជម្រះ**

**ហត្ថលេខា និងត្រា:** [redacted]

..........................................................................................................................

(បានចម្លងត្រឹមត្រូវតាមច្បាប់ដើម)

ថ្ងៃពុធ ១០ កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

កំពង់ចាម, ថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣

**ក្រឡាបញ្ជីសវនាការ**

[redacted]

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

[redacted]